# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់



www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបហិរញ្ញវត្ថុសាធារណៈនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ស្ដីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី២
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតការិយាល័យច្រកចេញ ចូលតែមួយ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅ:

- កំណត់ជាថ្មីនូវកម្រិតប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតការិយាល័យច្រកចេញ ចូលតែមួយ
- កំណត់វិធាននៃការបើកផ្ដល់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានបង្កើតការិយាល័យច្រកចេញ ចូលតែមួយ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តគ្របដណ្ដប់លើសមាជិកក្រុមប្រឹក្សារាជធានី សមាជិកក្រុមប្រឹក្សាខេត្ត សមាជិកក្រុមប្រឹក្សាក្រុង សមាជិកក្រុមប្រឹក្សាស្រុក សមាជិកក្រុមប្រឹក្សាខណ្ឌ សមាជិកក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាសង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតការិយាល័យច្រកចេញ ចូលតែមួយ ដែលកំពុងស្ថិតក្នុងមុខតំណែង។



www.pheakdeylaw.com

## ជំពូកទី២
## ការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែ

**មាត្រា៤ ..**

ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ ត្រូវបានកំណត់ដូចខាងក្រោម:

| ល.រ | បរិយាយ | ប្រាក់ឧបត្ថម្ភ(រៀល) |
|---|---|---|
| ១ | ប្រធានក្រុមប្រឹក្សារាជធានី<br>ប្រធានក្រុមប្រឹក្សាខេត្ត | ១ ០៩០ ០០០ |
| ២ | សមាជិកក្រុមប្រឹក្សារាជធានី<br>សមាជិកក្រុមប្រឹក្សាខេត្ត | ៨៧០ ០០០ |
| ៣ | ប្រធានក្រុមប្រឹក្សាក្រុង<br>ប្រធានក្រុមប្រឹក្សាស្រុក<br>ប្រធានក្រុមប្រឹក្សាខណ្ឌ | ៨១០ ០០០ |
| ៤ | សមាជិកក្រុមប្រឹក្សាក្រុង<br>សមាជិកក្រុមប្រឹក្សាស្រុក<br>សមាជិកក្រុមប្រឹក្សាខណ្ឌ | ៦៥០ ០០០ |
| ៥ | មេឃុំ<br>ចៅសង្កាត់ | ៧៥០ ០០០ |
| ៦ | ជំទប់ទី១<br>ចៅសង្កាត់រងទី១<br>ជំទប់ទី២<br>ចៅសង្កាត់រងទី២ | ៥៥០ ០០០ |
| ៧ | សមាជិកក្រុមប្រឹក្សាឃុំ<br>សមាជិកក្រុមប្រឹក្សាសង្កាត់ | ៤៨០ ០០០ |
| ៨ | មេភូមិ | ២០០ ០០០ |
| ៩ | អនុប្រធានភូមិ | ១៦០ ០០០ |
| ១០ | សមាជិកភូមិ | ១៤០ ០០០ |

**មាត្រា៥ ..**

ប្រាក់ឧបត្ថម្ភប្រចាំខែផ្តល់ជូនប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានបង្កើតការិយាល័យច្រកចេញ ចូលតែមួយ ត្រូវបានកំណត់ចំនួន៦៥០ ០០០(ប្រាំមួយសែនប្រាំម៉ឺន)រៀល។

**មាត្រា៦ ..**

ប្រាក់ឧបត្ថម្ភប្រចាំខែដែលមានកំណត់ក្នុងមាត្រា៤និងមាត្រា៥នៃអនុក្រឹត្យនេះ ត្រូវចាប់អនុវត្តពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦តទៅ។

ការកែសម្រួលប្រាក់ឧបត្ថម្ភប្រចាំខែខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។/



www.pheakdeylaw.com

## ជំពូកទី៣
## វិធាននៃការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ

**មាត្រា៧ .-**

ការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែដែលមានកំណត់ក្នុងមាត្រា៤និងមាត្រា៥នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមប្រព័ន្ធធនាគារ។

ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ត្រូវសហការរៀបចំការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែតាមប្រព័ន្ធធនាគារឱ្យបានរួចរាល់ក្នុងឆ្នាំ២០១៦។

**មាត្រា៨ .-**

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋដែលជាមន្ត្រីរាជការមិនទាន់ចូលនិវត្តន៍ ត្រូវទទួលបានប្រាក់បៀវត្សមូលដ្ឋាននិងប្រាក់វិភាជន៍គ្រួសារនៅអង្គភាពដើម ព្រមទាំងប្រាក់ឧបត្ថម្ភប្រចាំខែដូចមានកំណត់ក្នុងអនុក្រឹត្យនេះ។

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋមកពីមន្ត្រីរាជការដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ឬបាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារក្នុងក្របខណ្ឌដើម សាមីខ្លួនត្រូវទទួលបានប្រាក់សោធននិវត្តន៍ ឬប្រាក់បាត់បង់សម្បទាវិជ្ជាជីវៈ ឬប្រាក់បាត់បង់សមត្ថភាពការងារ និងប្រាក់ឧបត្ថម្ភផ្សេងៗ ទៅតាមការកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងប្រាក់ឧបត្ថម្ភប្រចាំខែដូចមានកំណត់ក្នុងអនុក្រឹត្យនេះ។

**មាត្រា៩ .-**

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋដែលមានមុខតំណែងផ្សេងទៀតជាទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ អាចទទួលប្រាក់ឧបត្ថម្ភប្រចាំខែឬប្រាក់បំណាច់មុខងារតែមួយប៉ុណ្ណោះ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

អនុក្រឹត្យលេខ២១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ៣៤១ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ អនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងអនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភជូនប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានបង្កើតការិយាល័យច្រកចេញ ចូលតែមួយ ត្រូវទុកជានិរាករណ៍ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦។



www.pheakdeylaw.com

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** |
|---|---|---|
| **សម្តេចក្រឡាហោម ស ខេង** | **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com